# ថ្នាំបង្ការជំងឺអុតស្វាប្រភេទ JYNNEOS
# សំណួរដែលបានសួរជាញឹកញាប់

## 1. តើថ្នាំបង្ការជំងឺអុតស្វាប្រភេទ JYNNEOS គឺជាអ្វី?

JYNNEOS គឺជាថ្នាំបង្ការដែលមានចំនួន 2 ដូស ហើយដែលបានទទួលការអនុម័តឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារនិងឱសថ (FDA) សម្រាប់ការទប់ស្កាត់ជំងឺអុតស្វា និងជំងឺអុតតូច (smallpox) ចំពោះមនុស្សទាំងឡាយដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។ ថ្នាំបង្ការនេះក៏បានទទួលការអនុញ្ញាតឱ្យប្រើប្រាស់ជាបន្ទាន់ (EUA) របស់ FDA ចំពោះអ្នកដែលមានអាយុក្រោម 18 ឆ្នាំ ផងដែរ។

- ប្រសិនបើមានការផ្តល់ជូនថ្នាំបង្ការប្រភេទ JYNNEOS *មុនពេល*មនុស្សម្នាក់បានប៉ះពាល់ទៅនឹងមេរោគអុតស្វានោះ ថ្នាំបង្ការប្រភេទនេះជួយការពារពួកគេពីការឆ្លងជំងឺអុតស្វា។
- ប្រសិនបើមានការផ្តល់ជូនភ្លាមៗ *ក្រោយពេល*ពួកគេបានប៉ះពាល់ទៅនឹងមេរោគអុតស្វានោះ (ល្អបំផុតក្នុងអំឡុងពេល 4 ថ្ងៃ) ថ្នាំបង្ការប្រភេទនេះអាចនឹងជួយទប់ស្កាត់ការកើតជំងឺ ឬធ្វើឱ្យជំងឺនោះមិនសូវមានកម្រិតធ្ងន់ធ្ងរ។

កំណត់សម្គាល់៖ ប្រសិនបើបុគ្គលម្នាក់មានរោគសញ្ញានានានៃជំងឺអុតស្វារួចហើយនោះ ពួកគេគឺហួសពេលវេលាសម្រាប់ទទួលចាក់ថ្នាំបង្ការហើយ។ ពួកគេគួរតែជួបជាមួយនឹងគ្រូពេទ្យសម្រាប់ការធ្វើតេស្ត និងសម្រាប់ដំបូន្មានទាក់ទងនឹងការព្យាបាលវិញ។

ថ្នាំបង្ការប្រភេទ JYNNEOS ត្រូវបានផលិតឡើងដោយប្រើប្រាស់មេរោគអុតគោ (vaccinia virus)។ នេះគឺជាមេរោគដែលទាក់ទងទៅនឹងមេរោគអុតស្វា និងមេរោគអុតតូច។ មេរោគអុតគោនេះត្រូវបានធ្វើឱ្យទន់ខ្សោយ ដូច្នេះមេរោគនេះមិនអាចបណ្តាលឱ្យកើតមានជំងឺអុតគោ ឬជំងឺអុតតូច ឬក៏ជំងឺអុតស្វាចំពោះអ្នកដែលទទួលចាក់ថ្នាំបង្ការ ឬអ្នកដែលនៅជិតពួកគេនោះទេ។

ថ្នាំបង្ការមួយដែលមានឈ្មោះថា ACAM2000 បានទទួលការអនុម័តឱ្យប្រើប្រាស់ដោយ FDA ដើម្បីទប់ស្កាត់ជំងឺអុតតូច ប៉ុន្តែក៏អាចមានការប្រើប្រាស់សម្រាប់ទប់ស្កាត់ជំងឺអុតស្វាផងដែរ។ ដោយសារតែមិនមានការប្រើប្រាស់ថ្នាំបង្ការប្រភេទ ACAM2000 ក្នុងការទប់ស្កាត់ជំងឺអុតស្វានៅក្នុងសហរដ្ឋអាមេរិកនាពេលនេះ បញ្ជីសំណួរដែលបានសួរជាញឹកញាប់នេះ សម្តៅទៅលើថ្នាំបង្ការប្រភេទ JYNNEOS តែប៉ុណ្ណោះ។

## 2. តើថ្នាំបង្ការនេះមានការផ្តល់ជូនយ៉ាងដូចម្តេចខ្លះ?

មានការផ្តល់ជូនថ្នាំបង្ការប្រភេទ JYNNEOS ដោយការចាក់តាមម្ជុល។ មានវិធីសាស្ត្រពីរយ៉ាងផ្សេងគ្នា ដែលអាចប្រើប្រាស់បាន៖

- **ការចាក់នៅក្រោមស្រទាប់ស្បែក (subcutaneous injection)**។ នេះមានន័យថាមានការចាក់ថ្នាំបង្ការនៅក្រោមស្បែក ទៅក្នុងដើមដៃផ្នែកខាងលើ។ វិធីសាស្ត្រនេះមានប្រើប្រាស់សម្រាប់មនុស្សទាំងឡាយដែលមានអាយុតិចជាង 18 ឆ្នាំ និងមនុស្សទាំងឡាយណាដែលធ្លាប់មានស្លាកស្នាមផ្លែសាច់ (keloid scars)។ ស្លាកស្នាមផ្លែសាច់នេះ គឺជាស្លាកស្នាមក្រាស់ ហើយពកឡើងមួយ ដែលកើតមានក្រោយពេលមានការខូចខាតស្បែក ដូចជាការមុត ឬការចាក់ធ្លុះ ឬក៏ការវះកាត់។
- **ការចាក់នៅចន្លោះស្រទាប់ស្បែក (intradermal injection)**។ នេះមានន័យថាមានការចាក់ថ្នាំបង្ការនៅចន្លោះស្រទាប់ស្បែក។ វិធីសាស្ត្រនេះប្រើប្រាស់សម្រាប់មនុស្សភាគច្រើនដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។ មនុស្សទាំងឡាយណាដែលទទួលចាក់ថ្នាំបង្ការដោយរបៀបនេះ អាចជ្រើសរើសទីតាំង 3 កន្លែងសម្រាប់ទទួលចាក់៖ នៅលើកំភួនដៃ (នៅផ្នែកខាងក្នុងកំភួនដៃ ចន្លោះពីកដៃទៅកែងដៃ) ឬនៅលើខ្នងផ្នែកខាងលើ ប៉ុន្តែនៅក្រោមឆ្អឹងស្មា ឬក៏ទៅក្នុងសាច់ដុំស្មា (deltoid)។ អ្នកអាចពិនិត្យមើលរូបភាពផ្សេងៗអំពីមនុស្សដែលបានទទួលចាក់ថ្នាំបង្ការនៅលើ កំភួនដៃ ឬខ្នងផ្នែកខាងលើ ឬក៏ ស្មា។

នាពេលបច្ចុប្បន្ននេះ ការចាក់នៅក្នុងស្រទាប់ស្បែកគឺជាវិធីសាស្ត្រដែលមានការប្រើប្រាស់សម្រាប់មនុស្សភាគច្រើនដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ប៉ុន្តែ ប្រសិនបើអ្នកព្រួយបារម្ភចំពោះស្លាកស្នាមផ្លែសាច់ ឬអ្នកពេញចិត្តទទួលចាក់ថ្នាំបង្ការនៅក្រោមស្បែកច្រើនជាងនោះ អ្នកអាចទទួលបាន។ សូមប្រាកដថាអ្នកប្រាប់ទៅដល់អ្នកផ្តល់ថ្នាំបង្ការអំពីចំណូលចិត្តរបស់អ្នក។

## 3. តើខ្ញុំត្រូវការចាក់ចំនួនប៉ុន្មានដូស?

ថ្នាំបង្ការប្រភេទ JYNNEOS មានផ្តល់ជូនជាចំនួនពីរដូស ក្នុងចន្លោះរយៈពេលយ៉ាងហោចណាស់ 4 សប្តាហ៍ពីគ្នា។ បុគ្គលម្នាក់នឹងចាប់ផ្តើមបង្កើតប្រព័ន្ធការពារក្នុងរយៈពេលប៉ុន្មានថ្ងៃឬប៉ុន្មានសប្តាហ៍ បន្ទាប់ពីការចាក់ដូសទីមួយរួច ប៉ុន្តែពួកគេនឹងមិនទាន់មានប្រព័ន្ធការពារខ្ពស់បំផុតនោះទេ រហូតដល់រយៈពេលពីរសប្តាហ៍ក្រោយពីការចាក់ដូសទីពីរ។ នេះគឺជាពេលដែលមានការចាត់ទុកថា អ្នកបានចាក់ថ្នាំបង្ការពេញលេញ។

ការបន្តចាត់វិធានការណ៍ផ្សេងៗទៀតដើម្បីកាត់បន្ថយកម្រិតហានិភ័យរបស់អ្នក បើទោះបីជាក្រោយពេលដែលអ្នកបានចាក់ថ្នាំបង្ការពេញលេញហើយនោះ គឺនៅតែជាការសំខាន់។

## 4. តើថ្នាំបង្ការដំណើរការបានល្អប៉ុណ្ណាដែរ?

ពួកយើងនៅមិនទាន់មានទិន្នន័យពីពិភពពិតជាក់ស្តែងគ្រប់គ្រាន់នៅឡើយទេ ដើម្បីនិយាយថាថ្នាំបង្ការការពារមនុស្សទាំងឡាយបានល្អប៉ុណ្ណាពីការឆ្លងជំងឺអុតស្វា ក្នុងអំឡុងពេលនៃការផ្ទុះឡើងនៃជំងឺនាពេលឥឡូវនេះ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សានាពេលថ្មីៗនេះ មួយ ដោយមជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) បានបង្ហាញថា សម្រាប់រាល់មនុស្សចំនួន 1 រូបដែលមានការឆ្លងមេរោគ ក្នុងចំណោមមនុស្សទាំងឡាយដែលបានទទួលចាក់ថ្នាំបង្ការប្រភេទ JYNNEOS ចំនួនមួយដូសនោះ មានការឆ្លងមេរោគចំនួន 14 ករណី ក្នុងចំណោមអ្នកដែលមិនបានទទួលចាក់ថ្នាំបង្ការ។ ទិន្នន័យចាស់ៗមកពីទ្វីបអាហ្វ្រិកបង្ហាញថាថ្នាំបង្ការប្រភេទ JYNNEOS មានប្រសិទ្ធិភាពយ៉ាងហោចណាស់ 85% ក្នុងការការពារមនុស្សទាំងឡាយពីជំងឺអុតស្វា នៅពេលដែលមានការផ្តល់ជូនថ្នាំបង្ការមុនពេលការប៉ះពាល់ទៅនឹងមេរោគ។

ការទទួលចាក់ថ្នាំបង្ការអាចនឹងទប់ស្កាត់បុគ្គលម្នាក់ដែលបានប៉ះពាល់ទៅនឹងមេរោគអុតស្វា ពីការកើតមានជំងឺនេះ ប្រសិនបើមានការទទួលចាក់ថ្នាំបង្ការនោះក្នុងអំឡុងពេល 4 ថ្ងៃពីការប៉ះពាល់ទៅនឹងមេរោគ។ ប្រសិនបើបុគ្គលម្នាក់នោះទទួលចាក់ថ្នាំបង្ការក្នុងចន្លោះពេលពី 4 ទៅ 14 ថ្ងៃក្រោយពីការប៉ះពាល់ទៅនឹងមេរោគនោះ ថ្នាំបង្ការមិនទំនងជាអាចទប់ស្កាត់ការឆ្លងមេរោគទេ ប៉ុន្តែប្រសិនបើបុគ្គលនោះឆ្លងជំងឺអុតស្វា រោគសញ្ញានានារបស់ពួកគេអាចនឹងមានកម្រិតស្រាលជាងមុន។

មិនមានការដឹងថាថ្នាំបង្ការនេះដំណើរការឡើយ ប្រសិនបើមានការផ្តល់ជូនចាក់ថ្នាំបង្ការក្រោយពេលបុគ្គលម្នាក់មានរោគសញ្ញានានានៃជំងឺអុតស្វារួចហើយនោះ។

ដោយសារតែពួកយើងនៅតែកំពុងសិក្សាអំពីថា តើថ្នាំបង្ការដំណើរការបានល្អប៉ុណ្ណាក្នុងអំឡុងពេលនៃការផ្ទុះឡើងនៃជំងឺនេះ ការបន្តអនុវត្តវិធានការណ៍ផ្សេងៗដើម្បីកាត់បន្ថយកម្រិតហានិភ័យរបស់អ្នក ទោះជាក្រោយពេលអ្នកបានចាក់ថ្នាំបង្ការពេញលេញហើយក៏ដោយនោះ គឺជាការសំខាន់។

## 5. តើអ្នកណាខ្លះគួរតែទទួលចាក់ថ្នាំបង្ការ?

មានការណែនាំឱ្យមនុស្សទាំងឡាយដែលបានប៉ះពាល់ទៅនឹងមេរោគអុតស្វា និងមនុស្សទាំងឡាយដែលអាចនឹងប្រឈមនឹងហានិភ័យនៃការឆ្លងជំងឺអុតស្វានាពេលនេះ ឬនាពេលអនាគត ទទួលចាក់ថ្នាំបង្ការ។

**បុគ្គលទាំងឡាយខាងក្រោមនេះ មានសិទ្ធិអាចទទួលចាក់ថ្នាំបង្ការបាន៖**

- បុរស ឬបុគ្គលដែលបានផ្លាស់ប្តូរភេទខុសពីដើមកំណើត (transgender) ណាម្នាក់ ដែលរួមភេទជាមួយនឹងបុរស ឬបុគ្គលដែលបានផ្លាស់ប្តូរភេទខុសពីដើមកំណើតផ្សេងៗទៀត
- បុគ្គលទាំងឡាយណាដែលមានភេទណាក៏ដោយ ឬស្រឡាញ់ភេទណាក៏ដោយ ហើយដែលចូលរួមក្នុងការរួមភេទជាលក្ខណៈជំនួញ និង/ឬជាលក្ខណៈដោះដូរ (ឧ. ការរួមភេទដើម្បីទទួលបានប្រាក់ ទីជម្រក ម្ហូបអាហារ ឬក៏របស់របរឬតម្រូវការផ្សេងទៀត) ឬក៏រួមភេទដែលជាប់ពាក់ព័ន្ធជាមួយនឹងព្រឹត្តិការណ៍សាធារណៈធំមួយ
- បុគ្គលទាំងឡាយណាដែលកំពុងមានមេរោគហ៊ីវ (HIV) ជាពិសេសអ្នកមានជំងឺ HIV ដែលមិនបានគ្រប់គ្រងត្រឹមត្រូវ ឬមានកម្រិតធ្ងន់ធ្ងរ
- បុគ្គលទាំងឡាយណាដែលមានការប៉ះពាល់ស្បែកនឹងស្បែក ឬការប៉ះពាល់ដោយស្និទ្ធស្នាល ជាមួយនឹងបុគ្គលណាម្នាក់ដែលមានការសង្ស័យថាមានជំងឺអុតស្វា ឬមានការបញ្ជាក់ច្បាស់លាស់ថាមានជំងឺនេះ រួមទាំងអ្នកដែលមិនទាន់មានការបញ្ជាក់ច្បាស់លាស់នៅឡើយ ដោយនាយកដ្ឋានសុខភាពសាធារណៈ (Public Health) ផងដែរ
- ដៃគូរួមភេទរបស់បុគ្គលទាំងឡាយនៅក្នុងក្រុមផ្សេងៗខាងលើ
- បុគ្គលទាំងឡាយណាដែលរំពឹងទុកថានឹងស្ថិតនៅក្នុងក្រុមផ្សេងៗណាមួយខាងលើ
- បុគ្គលទាំងឡាយណាដែលធ្វើការងារជាក់លាក់មួយចំនួន រួមមាន៖
  - អ្នកដែលធ្វើការជាមួយនឹងមេរោគជំងឺអុតប្រភេទ orthopoxviruses ឬធ្វើតេស្តសម្រាប់មេរោគជំងឺអុតប្រភេទនេះ នៅក្នុងមន្ទីរពិសោធន៍ស្រាវជ្រាវ ឬមន្ទីរពិសោធន៍លក្ខណៈវេជ្ជសាស្ត្រ
  - បុគ្គលិកផ្នែកថែទាំសុខភាពដែលមើលថែទាំអ្នកដែលមានការបញ្ជាក់ច្បាស់លាស់ថាមានជំងឺអុតស្វា ឬមានការសង្ស័យថាមានជំងឺនេះ។ បុគ្គលិកទាំងនេះរួមមានទាំងគ្រូពេទ្យពិនិត្យអ្នកជំងឺផ្ទាល់ និងបុគ្គលិកផ្នែកសេវាកម្មសម្អាតបរិស្ថាន ផងដែរ។ សូមមើលសំណួរដែលបានសួរជាញឹកញាប់ *ខ្ញុំគឺជាបុគ្គលិកផ្នែកថែទាំសុខភាព។ តើខ្ញុំគួរតែទទួលចាក់ថ្នាំបង្ការ ដែរឬទេ?* ខាងក្រោម។

មនុស្សជាច្រើនថែមទៀត អាចនឹងក្លាយទៅជាមានសិទ្ធិទទួលចាក់ថ្នាំបង្ការបាននាពេលអនាគត។ សម្រាប់ព័ត៌មានថ្មីៗបំផុត សូមមើលគេហទំព័រ ph.lacounty.gov/monkeypox/vaccine.htm។

## 6. តើផលប៉ះពាល់នៃថ្នាំបង្ការប្រភេទ JYNNEOS មានអ្វីខ្លះ?

ផលប៉ះពាល់នៅត្រង់កន្លែងចាក់គឺជាការកើតមានទូទៅ ចំពោះការចាក់ថ្នាំប្រភេទ JYNNEOS ទាំងនៅក្រោមស្រទាប់ស្បែក (subdermal) និងការចាក់នៅចន្លោះស្រទាប់ស្បែក (intradermal)។ ផលប៉ះពាល់ទាំងនេះរួមមាន ការឡើងក្រហម ការឡើងហើម ការឈឺចាប់ ការឡើងរឹង និង/ឬការរមាស់។ រោគសញ្ញាទាំងនេះគឺកើតមានជាទូទៅផង ចំពោះការចាក់នៅក្នុងស្រទាប់ស្បែក។ សម្រាប់បុគ្គលមួយចំនួន ការរមាស់ ឬការឡើងហើមអាចកើតមានចន្លោះពេលពីប៉ុន្មានថ្ងៃ ទៅពីរឬបីសប្តាហ៍។ ផលប៉ះពាល់ផ្សេងៗទៀតអាចរួមមាន ការឈឺសាច់ដុំ ឈឺក្បាល ចង្អោរចង់ក្អួត គ្រុនរងា ឬមានអារម្មណ៍អស់កម្លាំង។ មានឱកាសបន្តិចបន្តួចក្នុងការកើតមានគ្រុនក្តៅផងដែរ។

ដូចគ្នាទៅនឹងថ្នាំពេទ្យណាមួយក៏ដោយ ថ្នាំបង្ការក៏មានឱកាសដ៏តូចមួយក្នុងការបណ្តាលឱ្យមានប្រតិកម្ម ឬការទាស់កម្រិតធ្ងន់ធ្ងរ។ ប្រសិនបើអ្នកមានសញ្ញានានានៃប្រតិកម្ម ឬការទាស់កម្រិតធ្ងន់ធ្ងរ (ដូចជាការឡើងកន្ទាលត្រអាក ការឡើងហើមមុខឬបំពង់ក ការពិបាកដកដង្ហើម បេះដូងលោតញាប់ ឬក៏ការវិលមុខ) សូមទូរស័ព្ទទៅលេខ **911 ជាបន្ទាន់** ឬក៏ទៅកាន់មន្ទីរពេទ្យដែលនៅជិតអ្នកបំផុត។ សម្រាប់ការព្រួយបារម្ភផ្សេងទៀត សូមទាក់ទងទៅអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព។

## 7. តើខ្ញុំអាចទទួលចាក់ថ្នាំបង្ការនេះ ក្នុងពេលតែមួយជាមួយនឹងថ្នាំបង្ការផ្សេងទៀតបាន ដែរឬទេ?

ចាស/បាទ។ អាចផ្តល់ជូនថ្នាំបង្ការប្រភេទ JYNNEOS មុនពេល ឬក្រោយពេល ឬក៏ក្នុងពេលតែមួយជាមួយនឹងថ្នាំបង្ការផ្សេងៗទៀតបាន។ ថ្នាំបង្ការទាំងនេះរួមមានថ្នាំបង្ការជំងឺគ្រុនផ្តាសាយធំ (flu) និងថ្នាំបង្ការជំងឺ COVID-19 ផងដែរ។

ប្រសិនបើអ្នកគឺជាមនុស្សភេទប្រុសដែលមានអាយុចាប់ពី 12 ទៅ 39 ឆ្នាំ អ្នកប្រហែលជាអាចពិចារណាលើការរង់ចាំរយៈពេល 4 សប្តាហ៍ បន្ទាប់ពីការទទួលចាក់ថ្នាំបង្ការប្រភេទ JYNNEOS មុនពេលការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។ ការធ្វើបែបនេះ គឺដោយសារតែអាចនឹងមានការកើនឡើងបន្តិចបន្តួចនៃកម្រិតហានិភ័យ ចំពោះបញ្ហា myocarditis (ការរលាកសាច់ដុំបេះដូង) ប្រសិនបើអ្នកទទួលចាក់ថ្នាំបង្ការផ្សេងៗក្នុងពេលជិតគ្នានោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកប្រឈមនឹងហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺអុតស្វា ឬមានការប៉ះពាល់ទៅនឹងមេរោគនាពេលថ្មីៗនេះ អ្នកគួរតែទទួលចាក់ថ្នាំបង្ការប្រភេទ JYNNEOS បើទោះបីជាអ្នកបានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 នាពេលថ្មីៗនេះហើយក៏ដោយ។

## 8. ខ្ញុំគឺជាបុគ្គលិកផ្នែកថែទាំសុខភាព។ តើខ្ញុំគួរតែទទួលចាក់ថ្នាំបង្ការ ដែរឬទេ?

ហានិភ័យនៃការចម្លងជំងឺអុតស្វា គឺមានកម្រិតទាបសម្រាប់បុគ្គលិកផ្នែកថែទាំសុខភាព (HCW) ប្រសិនបើពួកគេអនុវត្តតាមគំរូអនុវត្តន៍សម្រាប់ការគ្រប់គ្រងការឆ្លងមេរោគ ដែលសមស្រប។ ការធ្វើបែបនេះរួមមានទាំងការពាក់ឧបករណ៍ការពារផ្ទាល់ខ្លួន (PPE) ហើយនិងការអនុវត្តន៍វិធីសាស្ត្រប្រមូលសំណាកដែលប្រកបដោយសុវត្ថិភាព ផងដែរ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលិកផ្នែកថែទាំសុខភាពទាំងឡាយណាដែលមើលថែទាំអ្នកដែលមានការបញ្ជាក់ច្បាស់លាស់ថាមានជំងឺអុតស្វា ឬមានការសង្ស័យថាមានជំងឺនេះ គឺមានសិទ្ធិអាចទទួលចាក់ថ្នាំបង្ការបាន។ នេះរួមមានទាំងបុគ្គលិកផ្នែកថែទាំសុខភាពទាំងឡាយណាដែលទំនងជានឹងត្រូវប្រមូលសំណាកសម្រាប់មន្ទីរពិសោធន៍ពីអ្នកដែលមានជំងឺអុតស្វា (ឧ. បុគ្គលិកផ្នែកថែទាំសុខភាពដែលកំពុងធ្វើការនៅតាមគ្លីនិកផ្នែកសុខភាពផ្លូវភេទ ឬទីតាំងគ្លីនិកទាំងឡាយណាដែលបម្រើការជូនប្រជាជនដែលប្រឈមនឹងហានិភ័យ)។

បុគ្គលិកដែលគ្រាន់តែជាអ្នកចាក់ថ្នាំបង្ការប្រភេទ JYNNEOS ប៉ុន្តែមិនមើលថែទាំអ្នកដែលមានការបញ្ជាក់ច្បាស់លាស់ថាមានជំងឺអុតស្វា ឬមានការសង្ស័យថាមានជំងឺនេះ មិនមានសិទ្ធិក្នុងការទទួលចាក់ថ្នាំបង្ការជំងឺអុតស្វានោះទេ។

អាចមានការណែនាំឱ្យប្រើប្រាស់ថ្នាំសម្រាប់ទប់ស្កាត់ជំងឺក្រោយពេលប៉ះពាល់ទៅនឹងមេរោគ (postexposure prophylaxis/PEP) សម្រាប់បុគ្គលិកផ្នែកថែទាំសុខភាពទាំងឡាយ បន្ទាប់ពីមានការប៉ះពាល់ទៅនឹងមេរោគទាក់ទងនឹងការធ្វើការងារជាក់លាក់មួយចំនួន។ សូមមើល តារាងហានិភ័យនៃការប៉ះពាល់ទៅនឹងមេរោគកម្រិតខ្ពស់ និងមធ្យម។

### 9. ប្រសិនបើខ្ញុំមានរោគសញ្ញានៃជំងឺអុតស្វា តើខ្ញុំគួរតែទទួលចាក់ថ្នាំបង្ការ ដែរឬទេ?

ទេ។ ប្រសិនបើអ្នកមាន រោគសញ្ញានានានៃជំងឺអុតស្វា អ្នកមិនគួរទទួលចាក់ថ្នាំបង្ការជំងឺអុតស្វានោះទេ។ ចូរពិគ្រោះជាមួយនឹងគ្រូពេទ្យអំពីរោគសញ្ញានានារបស់អ្នក ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ប្រសិនបើអ្នកមិនមានគ្រូពេទ្យប្រចាំខ្លួន ឬធានារ៉ាប់រងសុខភាពទេនោះ អ្នកអាចទៅកាន់ គ្លីនិកផ្នែកសុខភាពផ្លូវភេទ មួយរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health)។ សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health Call Center) តាមរយៈលេខ 1-833-540-0473 (មានបើកបម្រើការជូន 7 ថ្ងៃក្នុងមួយសប្តាហ៍ ចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់)។

### 10. ខ្ញុំធ្លាប់មានជំងឺអុតស្វារួចហើយ តើខ្ញុំគួរតែទទួលចាក់ថ្នាំបង្ការ ដែរឬទេ?

ទេ។ ផ្អែកទៅលើព័ត៌មានដែលអាចរកបាននាពេលនេះ ប្រសិនបើអ្នកធ្លាប់មានជំងឺអុតស្វារួចហើយនោះ អ្នកមានប្រព័ន្ធការពារពីការឆ្លងជំងឺនេះម្តងទៀត។ អ្នកមាន "ភាពស៊ាំបែបធម្មជាតិ"។ មិនមានការណែនាំឱ្យទទួលចាក់ថ្នាំបង្ការទេ នាពេលនេះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកគួរតែពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ថាតើអ្នកគួរតែទទួលចាក់ថ្នាំបង្ការ ឬទេ។

### 11. ប្រសិនបើខ្ញុំឆ្លងជំងឺអុតស្វាក្រោយពេលទទួលចាក់ថ្នាំបង្ការដូសទីមួយ តើខ្ញុំគួរតែទទួលចាក់ដូសទីពីរ ដែរឬទេ?

ផ្អែកទៅលើព័ត៌មានដែលអាចរកបាននាពេលនេះ ក្រោយពេលអ្នកធ្លាប់មានជំងឺអុតស្វារួចហើយនោះ អ្នកមានប្រព័ន្ធការពារពីការឆ្លងជំងឺនេះម្តងទៀត។ នេះមានន័យថាអ្នកមិនត្រូវការទទួលចាក់ដូសទីពីរនោះទេ។ ប្រសិនបើអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយ (អ្នកមានប្រព័ន្ធភាពស៊ាំមួយដែលទន់ខ្សោយ) ចូរពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ថាតើអ្នកគួរតែទទួលចាក់ដូសទីពីរ ឬទេ។

### 12. ប្រសិនបើខ្ញុំធ្លាប់ទទួលចាក់ថ្នាំបង្ការជំងឺអុតតូច កាលពីច្រើនឆ្នាំកន្លងមកហើយ តើខ្ញុំគួរតែទទួលចាក់ថ្នាំបង្ការជំងឺអុតស្វាដដែល មែនឬទេ?

ចាស/បាទ។ បុគ្គលទាំងឡាយណាដែលបានទទួលចាក់ថ្នាំបង្ការជំងឺអុតតូច មុនពេលការផ្ទុះឡើងនៃជំងឺអុតស្វានេះ គួរតែទទួលចាក់ថ្នាំបង្ការជំងឺអុតស្វាដដែល។ ការធ្វើបែបនេះគឺដោយសារតែប្រព័ន្ធការពារដែលទទួលបានពីថ្នាំបង្ការជំងឺអុតតូចនោះ អាចមានការចុះអន់ថយទៅតាមពេលវេលា។

### 13. តើខ្ញុំអាចទទួលចាក់ថ្នាំបង្ការបាន ដែរឬទេ ប្រសិនបើខ្ញុំមានប្រព័ន្ធភាពស៊ាំចុះខ្សោយ និង/ឬមានជំងឺហ៊ីវ?

ចាស/បាទ។ ការទទួលចាក់ថ្នាំបង្ការគឺជាការសំខាន់ ពីព្រោះបុគ្គលទាំងឡាយដែលមានប្រព័ន្ធភាពស៊ាំទន់ខ្សោយ ដូចជាបុគ្គលដែលមានជំងឺហ៊ីវ (HIV) កម្រិតធ្ងន់ធ្ងរ ឬមិនបានគ្រប់គ្រងត្រឹមត្រូវ ឬក៏អ្នកដែលប្រឈមនឹងហានិភ័យខ្ពស់ជាងមុនក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ប្រសិនបើពួកគេឆ្លងជំងឺអុតស្វានោះ។ មានការសិក្សាស្រាវជ្រាវថ្នាំបង្ការប្រភេទ JYNNEOS ចំពោះអ្នកដែលមានជំងឺហ៊ីវ ហើយមិនឃើញថាមានប្រតិកម្មអវិជ្ជមានកម្រិតធ្ងន់ធ្ងរកើតឡើងនោះទេ។

ចូរកត់សម្គាល់ជាសំខាន់ថា ប្រសិនបើអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយ អ្នកមិនសូវទំនងជាអាចបង្កើតការឆ្លើយតបនៃភាពស៊ាំដែលខ្លាំងមួយ ក្រោយការទទួលចាក់ថ្នាំបង្ការនោះទេ។ នេះមានន័យថាការអនុវត្តន៍ជំហានផ្សេងៗទៀតដើម្បីការពារអ្នកពីការឆ្លងជំងឺអុតស្វានោះ គឺជាការសំខាន់។

### 14. តើខ្ញុំអាចទទួលចាក់ថ្នាំបង្ការបាន ដែរឬទេ ប្រសិនបើខ្ញុំមានរោគត្រអក?

ចាស/បាទ មានការសិក្សាស្រាវជ្រាវថ្នាំបង្ការប្រភេទ JYNNEOS ចំពោះអ្នកដែលមានរោគសើស្បែកដែលបង្កឱ្យមានស្បែកស្ងួត រមាស់ និងមានការរលាក (atopic dermatitis) (ឬរោគត្រអក [eczema]) ហើយមិនឃើញថាមានប្រតិកម្មអវិជ្ជមានកម្រិតធ្ងន់ធ្ងរកើតឡើងនោះទេ។ បុគ្គលទាំងឡាយដែលមានស្ថានភាពទាំងនេះ អាចនឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ប្រសិនបើពួកគេពិតជាកើតជំងឺអុតស្វានោះ។

## 15. តើខ្ញុំគួរតែទទួលចាក់ថ្នាំបង្ការ ដែរឬទេ ប្រសិនបើខ្ញុំកំពុងមានផ្ទៃពោះ ឬប្រហែលជានឹងអាចមានផ្ទៃពោះ?

ប្រសិនបើអ្នកកំពុងមានផ្ទៃពោះ ហើយអ្នកបានប៉ះពាល់ទៅនឹងមេរោគអុតស្វានោះ មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យអ្នកពិចារណាលើការទទួលចាក់ថ្នាំបង្ការ។ នេះគឺពីព្រោះតែមេរោគអុតស្វាអាចចម្លងទៅដល់ទារកនៅក្នុងផ្ទៃបាន ក្នុងអំឡុងពេលមានផ្ទៃពោះ ឬចម្លងទៅដល់ទារកដែលទើបនឹងកើត ដោយការប៉ះពាល់ជិតស្និទ្ធ ក្នុងអំឡុងពេល និងក្រោយពេលសម្រាល។ មានការរាយការណ៍ថាអ្នកដែលកើតជំងឺអុតស្វានៅពេលដែលពួកគេមានផ្ទៃពោះនោះ មានបញ្ហាកើតមិនគ្រប់ខែ ការរលូតកូន ទារកស្លាប់ក្នុងផ្ទៃ ហើយនិងការឆ្លងមេរោគអុតស្វាទៅដល់ទារកផងដែរ។ នៅមិនទាន់មានការយល់ដឹងទេ ថាចំណុចនេះកើតមានឡើងញឹកញាប់ប៉ុណ្ណា ឬប្រហែលជាអាចនឹងកើតមានក្នុងអំឡុងពេលនៃការផ្ទុះឡើងនៃជំងឺនេះ ឬទេ។ ទិន្នន័យចំពោះហានិភ័យផ្សេងៗនៃការទទួលចាក់ថ្នាំបង្ការប្រភេទ JYNNEOS ក្នុងអំឡុងពេលមានផ្ទៃពោះនោះ គឺនៅមានកំណត់។ ប្រសិនបើអ្នកមានសំណួរអំពីការចាក់ថ្នាំបង្ការ សូមពិគ្រោះជាមួយនឹងផ្តល់សេវាកម្មថែទាំសុខភាព។ ថ្នាំបង្ការទំនងជានឹងដំណើរការបានកាន់តែល្អ នៅពេលដែលអ្នកទទួលចាក់កាន់តែឆាប់ បន្ទាប់ពីអ្នកបានប៉ះពាល់ទៅនឹងមេរោគរួច។

## 16. តើខ្ញុំអាចទទួលចាក់ថ្នាំបង្ការបាន ដែរឬទេ ប្រសិនបើខ្ញុំកំពុងបំបៅកូនដោយទឹកដោះ?

ប្រសិនបើអ្នកបានប៉ះពាល់ទៅនឹងមេរោគអុតស្វា ហើយអ្នកកំពុងបំបៅកូនដោយទឹកដោះនោះ អ្នកគួរតែទទួលចាក់ថ្នាំបង្ការ។ ទិន្នន័យអំពីឥទ្ធិពលនៃថ្នាំបង្ការប្រភេទ JYNNEOS ចំពោះទារកដែលបៅដោះ ឬការផលិតទឹកដោះនោះ គឺមិនទាន់អាចរកបាននៅឡើយទេ។ ការដែលថាថ្នាំបង្ការប្រភេទ JYNNEOS អាចជ្រាបចូលទៅក្នុងទឹកដោះមនុស្សមែនឬអត់នោះ ក៏មិនទាន់ដឹងផងដែរ។ ប៉ុន្តែដោយសារតែថ្នាំបង្ការនេះមិនមានផ្ទុកមេរោគដែលអាចបង្កើតខ្លួនទៅជាច្រើនចំណែកនោះ ការទទួលចាក់ថ្នាំបង្ការមិនអាចធ្វើឱ្យទារករបស់អ្នកឆ្លងមេរោគអុតស្វានោះទេ។

## 17. ដូសទីមួយរបស់ខ្ញុំគឺចាក់នៅក្រោមស្រទាប់ស្បែក (subcutaneous)។ តើដូសទីពីររបស់ខ្ញុំនឹងមានការចាក់ជូនយ៉ាងដូចម្តេច?

ប្រសិនបើអ្នកមានអាយុចាប់ពី 18 ឆ្នាំឡើងទៅនោះ ដូសទីពីរនឹងមានផ្តល់ជូនដោយការចាក់នៅចន្លោះស្រទាប់ស្បែក (intradermally) ដើម្បីបំពេញលំដាប់ថ្នាំបង្ការដែលមានចំនួនពីរដូសនេះ (សូមមើលសំណួរ *តើថ្នាំបង្ការនេះមានការផ្តល់ជូនយ៉ាងដូចម្តេចខ្លះ?*នៅខាងលើ)។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីស្លាកស្នាមផ្លែសាច់ (keloid scarring) ឬប្រសិនបើអ្នកពេញចិត្តទទួលចាក់ដូសទីពីរនៅក្រោមស្រទាប់ស្បែក (subcutaneously) ច្រើនជាង នោះអ្នកអាចទទួលចាក់ថ្នាំបង្ការដូសទីពីរនៅក្រោមស្រទាប់ស្បែកបាន។

## 18. តើខ្ញុំអាចចាក់ដូសទីពីររបស់ខ្ញុំនៅក្រោមស្រទាប់ស្បែក (subcutaneously) បាន ដែរឬទេ ប្រសិនបើខ្ញុំឈានដល់អាយុ 18 ឆ្នាំ បន្ទាប់ពីការទទួលចាក់ដូសទីមួយរួច?

ចាស/បាទ។ នៅពេលដែលអ្នកឈានដល់អាយុ 18 ឆ្នាំ ជាទូទៅ មានការផ្តល់ជូនថ្នាំបង្ការដោយការចាក់នៅចន្លោះស្រទាប់ស្បែក (intradermally)។ ប៉ុន្តែ ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការឡើងស្លាកស្នាមផ្លែសាច់ (keloid scarring) ឬប្រសិនបើអ្នកពេញចិត្តទទួលចាក់ថ្នាំនៅក្រោមស្រទាប់ស្បែក (subcutaneous) ច្រើនជាង នោះអ្នកអាចទទួលចាក់ថ្នាំបង្ការនៅក្រោមស្រទាប់ស្បែកបាន។ សូមប្រាកដថាអ្នកប្រាប់ទៅដល់អ្នកផ្តល់ថ្នាំបង្ការអំពីចំណូលចិត្តរបស់អ្នក។

## 19. តើខ្ញុំត្រូវការទទួលការអនុញ្ញាតពីឪពុកម្តាយរបស់ខ្ញុំដើម្បីទទួលចាក់ថ្នាំបង្ការ ដែរឬទេ?

នៅតាមទីតាំងរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health) ប្រសិនបើអ្នកមានអាយុចន្លោះពី 12 ទៅ 17 ឆ្នាំនោះ អ្នកអាចអនុញ្ញាតដើម្បីទទួលចាក់ថ្នាំបង្ការបាន ដោយចុះហត្ថលេខានៅលើ [បែបបទ] នេះ។ នៅតាមទីតាំងទាំងនេះ ប្រសិនបើអ្នកមានអាយុក្រោម 12 ឆ្នាំនោះ ឪពុកឬម្តាយម្នាក់ ឬអាណាព្យាបាលស្របច្បាប់ ឬក៏មនុស្សពេញវ័យដែលមានទំនួលខុសត្រូវម្នាក់ ត្រូវតែអមដំណើរទៅជាមួយនឹងអ្នក។ អ្នកក៏ត្រូវតែមាន [បែបបទនៃការអនុញ្ញាត] ដែលបានចុះហត្ថលេខាដោយឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់អ្នកផងដែរ។

## 20. តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែម នៅទីណាខ្លះ?

- គេហទំព័រទាក់ទងនឹងជំងឺអុតស្វា ph.lacounty.gov/Monkeypox | ទំព័រថ្នាំបង្ការជំងឺអុតស្វា របស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (LAC DPH)

- តារាងព័ត៌មានការពិតសម្រាប់អ្នកទទួលចាក់ថ្នាំបង្ការ និងអ្នកផ្ដល់ការមើលថែទាំ (សម្រាប់ការចាក់ថ្នាំបង្ការនៅចន្លោះស្រទាប់ស្បែក [intradermal] និងសម្រាប់អ្នកដែលមានអាយុក្រោម 18 ឆ្នាំ) របស់រដ្ឋបាលចំណីអាហារ និងឱសថ (FDA)
- សេចក្ដីថ្លែងការណ៍អំពីព័ត៌មានទាក់ទងនឹងថ្នាំបង្ការ (ចំពោះថ្នាំបង្ការដែលចាក់នៅក្រោមស្រទាប់ស្បែក [subcutaneous] សម្រាប់អ្នកដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ) នៅលើគេហទំព័រ ថ្នាំបង្ការប្រភេទ JYNNEOS – អ្វីដែលអ្នកត្រូវស្វែងយល់ របស់មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC)
- គេហទំព័រថ្នាំបង្ការជំងឺអុតស្វា CDC
- គេហទំព័រថ្នាំបង្ការជំងឺអុតស្វា របស់នាយកដ្ឋានសុខភាពសាធារណៈនៃរដ្ឋ California (CDPH)